ព្រឹត្តិបត្រព័ត៌មានបេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គម
National Social Security Fund

# ប.ស.ស ឆ្នាំទី ០៩

លេខ ២៥ ឆ្នាំ ២០១៩



ធានាសន្តិសុខប្រាក់ចំណូល

រួមចំណែកកាត់បន្ថយភាពក្រីក្រ

លើកកម្ពស់ស្ថិរភាពសង្គម

ទំនាក់ទំនងបន្ទាន់

**១២៨៦**

២៤ម៉ោង/៧ថ្ងៃ

## ព្រឹត្តិបត្រព័ត៌មាន

# ប.ស.ស

## មាតិកា


០១ ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី.......០១

០២ ប្រមុខរាជរដ្ឋាភិបាលអំពាវនាវឱ្យសហគ្រាស ក្រុមហ៊ុនទាំង.......០២

០៣ រាជរដ្ឋាភិបាលកំពុងរៀបចំច្បាប់របបសន្តិសុខសង្គម ដែល.........០៤

០៤ ឆ្នាំ២០១៨ ដែលទើបកន្លងផុតទៅថ្មីៗនេះ មានកម្មករនិយោ......០៦

០៥ ពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹក......០៨

០៦ ប.ស.ស ប្រគល់ប័ណ្ណសមាជិក ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជ.....១១

០៧ ប.ស.ស ប្រគល់ប័ណ្ណសមាជិក ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជ....១៣

០៨ ប.ស.ស ផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ជូនដល់មន្ត្រីរាជការ.......១៥

០៩ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយមូលដ្ឋានសុខាភិបាលកម្រិត.....១៧

១០ កិច្ច ប្រជុំពិភាក្សាលើការផ្តល់សេវា និងការទូទាត់ថ្លៃសេវា..........១៩

១១ ប.ស.ស ផ្តល់ប័ណ្ណ សមាជិករបស់ខ្លួនចំនួន ១២ ២៦០..........២១

១២ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់ កុំព្រួយបារម្ភ.......២៣

១៣ ពិធីប្រគល់-ទទួល ប័ណ្ណសមាជិក ប.ស.ស និងផ្សព្វផ្សាយ........២៥

១៤ ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល ប្រមាណជាង ២៥ពាន់...២៨

១៥ បេឡាជាតិរបបសន្តិសុខសង្គម ប្រគល់ប័ណ្ណសមាជិករបស់.......៣០

១៦ ពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹក.....៣២

១៧ ឆ្នាំ២០១៨ ប.ស.ស ទទួលបានពានរង្វាន់ ស្តីពីការទទួល........៣៤

១៨ កិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយស្តីពីការអនុវត្តរបប.........៣៧

១៩ គណៈប្រតិភូក្រសួងការងារ នៃសាធារណរដ្ឋកេនយ៉ា..............៣៩

២០ សកម្មភាពកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការអនុវត្តរបបសន្តិសុខ.......៤១

២១ លោក អគ្គបណ្ឌិត ប៊ុត សារង្ស (កូនមាសឪពុក).......................៤៥

២២ ៣យ៉ាង បញ្ជាក់ថា ហូបមើមត្រាវច្រើន មានប្រយោជន៍............៤៦









## រចនាសម្ព័ន្ធព្រឹត្តិបត្រ

### ឯកឧត្តម អ៊ុក សមវិទ្យា
### នាយក ប.ស.ស

| | |
|---|---|
| ចាងហ្វាង | ឯកឧត្តម ហេង សុផាន់ណារិទ្ធ |
| និពន្ធនាយក | លោក យ៉ាម យុទ្ធា |
| និពន្ធនាយករង | លោក យុន វិចិត្រ |
| | លោក នៅ សុមនា |
| | លោក វ៉ាន់ ចាន់ថន |
| លេខានិពន្ធ | កញ្ញា រ៉ាត់ ម៉ាលីកា |
| | លោក នាង ជូ |
| | លោក យន គន្ធា |
| | លោក អ៊ឹង លាងឆុង |
| | លោក លីម តក់ |
| ផ្នែកការីកុំព្យូទ័រ | លោក ប៊ុត ស៊ីម |
| | លោក យង់ សុខន |
| | លោក អ៊ុង ស៊ីវឿ |

# អង្គការលេខរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)





# ព្រះករុណាព្រះបាទ សម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន ម្ដាយ និង កុមារ ចំនួន ៣៤៥ នាក់ចូលក្រាបថ្វាយបង្គំគាល់

ក្នុងឱកាសទិវាជាតិសុខភាពមាតា និងទារក នៅព្រឹកថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៩ ព្រះករុណាព្រះបាទ សម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន ម្ដាយ និង កុមារ ចំនួន ៣៤៥ នាក់ ដែលមកពីខេត្តកំពង់ស្ពឺ និង ខេត្តកំពង់ឆ្នាំង ចូលក្រាបថ្វាយបង្គំគាល់ដើម្បីទទួលព្រះរាជអំណោយដ៏ថ្លៃថ្លាបំផុតនៅក្រោមដើមកណ្ដឹងដំរី ក្រោយដំណាក់ចាន់ ក្នុងព្រះបរមរាជវាំង៕













# ប្រមុខរាជរដ្ឋាភិបាលអំពាវនាវឱ្យសហគ្រាស ក្រុមហ៊ុនទាំងឡាយដែលមិនទាន់បានចុះបញ្ជី មកធ្វើការចុះបញ្ជីដើម្បីកម្មករទទួលបានផលប្រយោជន៍



**ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានធ្វើការអំពាវនាវឱ្យបណ្តារោងចក្រ សហគ្រាស ក្រុមហ៊ុន និងកសិដ្ឋានទាំងឡាយដែលមិនទាន់បានចុះបញ្ជី ត្រូវតែមកធ្វើការចុះបញ្ជី ដើម្បីធានាថាកម្មករត្រូវបានទទួលនូវផលប្រយោជន៍ពីគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល។ក្នុងខណៈអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ជាមួយ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ក្នុងមិទ្ទីងអបអរសាទរខួបទី ១០៨ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៩ ក្រោមប្រធានបទ (លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស) ដែលមានអ្នកចូលរួមប្រមាណជាង ៣ ០០០នាក់ នាព្រឹកថ្ងៃអង្គារ ១៤រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ នៅសាលមហោស្រពកោះពេជ្រ **សម្តេចតេជោ** ថ្លែងថា ចាប់ផ្តើមពីនយោបាយគាំពារសង្គមសម្រាប់ស្ត្រីមានផ្ទៃពោះគឺជាចំណុចដែលយើងត្រូវតែអនុវត្តន៍ឱ្យបានហ្មត់ចត់ នូវអ្វីដែលយើងបាននឹងកំពុងធ្វើរួចមកហើយសម្រាប់ស្ត្រីដែលបម្រើមុខងារជាមន្ត្រីរាជការស៊ីវិល និងនៅក្នុង




កងកម្លាំងប្រដាប់អាវុធត្រូវឱ្យពួកគាត់បានទទួលរបបឧបត្ថម្ភតាមការកំណត់របស់រដ្ឋនិងបានទទួលការឈប់សម្រាកតាមច្បាប់។ សម្រាប់ស្ត្រីដែលជាកម្មការិនី ត្រូវតែអនុវត្តន៍ឱ្យបានហ្មត់ចត់ជាមួយ និងការឈប់សម្រាករយៈពេលបីខែ ដោយទទួលបានប្រាក់បៀវត្សរ៍ ១២០ភាគរយ បូក និងការជួយឧបត្ថម្ភរបស់រាជរដ្ឋាភិបាលចំនួន ៤០ម៉ឺនរៀល សម្រាប់កូនម្នាក់ កូនភ្លោះ ៨០ម៉ឺនរៀល និងកូនបីចំនួន ១២០ម៉ឺនរៀល បូកនិងជំនួយឧបត្ថម្ភរបស់ខ្ញុំចំនួន៥លានរៀលថែមទៀត។

**សម្តេច** បានបន្តថាអ្វីដែលជាការអំពាវនាវរបស់ខ្ញុំយ៉ាងទទូច សូមឱ្យបណ្តាសហគ្រាស ក្រុមហ៊ុនទាំងឡាយដែលមិនទាន់បានចុះបញ្ជី ត្រូវតែធ្វើការចុះបញ្ជី ដើម្បីធានាថាកម្មករត្រូវបានទទួលនូវផលប្រយោជន៍ពីគោលនយោបាយគាំពារសង្គម ដោយទទួលបាននូវការពិនិត្យព្យាបាលដោយឥតគិតប្រាក់ជាពិសេសគឺសម្រាប់កម្មការិនី ដែលធ្វើការនៅទីកន្លែងនោះទទួលបាននូវអត្ថប្រយោជន៍ពីគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល សម្រាប់ស្ត្រីមានផ្ទៃពោះនិងឆ្លងទន្លេ។

**សម្តេចតេជោ** គូសបញ្ជាក់ថា ចំណុចនេះខ្ញុំស្នើឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមគ្នាជាមួយក្រសួងកិច្ចការនារី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការពិនិត្យមើលថា ក្នុងករណីដែលក្រុមហ៊ុននានា មិនទាន់បានចុះបញ្ជីទេ តើយើងអាចធ្វើទៅរួចទេ គឺធ្វើទៅមុនតែម្តង ជាមួយនិងការចុះស្រង់ស្ថិតិសម្រាប់ស្ត្រីដែលជាកម្មការិនីនៅតាមទីកន្លែងនានា ដើម្បីយើងផ្តល់ប័ណ្ណជូនពួកគាត់ ដើម្បីផ្តល់ការធានារ៉ាប់រងជាមួយ និងផលប្រយោជន៍របស់ពួកគាត់ នៅពេលដែលគាត់ឆ្លងទន្លេ ឬពិនិត្យព្យាបាលដោយឥតគិតប្រាក់។ ដូច្នេះកន្លែងណាដែលអាចធ្វើបានមុនគួរតែត្រូវធ្វើ ដែលក្នុងនោះគឺចាប់ផ្តើមពីស្ត្រីតែម្តង។ ជាងនេះទៀតនៅពេលខាងមុខនេះក៏ជាដំណាក់កាលដែលយើងដាក់ឱ្យអនុវត្តន៍នូវនយោបាយគាំពារសង្គមសម្រាប់ស្ត្រីក្រីក្រ ដែលមានផ្ទៃពោះ និងឆ្លងទន្លេ គឺចាប់ពីពេលដែលមានផ្ទៃពោះ ត្រូវទទួលបានការឧបត្ថម្ភ ៤ដង រហូតដល់ពេលឆ្លងទន្លេហើយនៅពេលឆ្លងទន្លេត្រូវបានទទួលបានការឧបត្ថម្ភ១ដង និងបន្ទាប់ពីការឆ្លងទន្លេរហូតដល់ទារកមានអាយុពីរឆ្នាំ ត្រូវទទួលបានការឧបត្ថម្ភចំនួន ១០ដងផ្សេងទៀត ដែលរាជរដ្ឋាភិបាលនឹងត្រូវបញ្ចេញសាច់ប្រាក់ទៅសម្រាប់ពួកគាត់រហូតទៅដល់ប្រមាណ ៧៦ម៉ឺនរៀល សម្រាប់មនុស្សម្នាក់។ ដូច្នេះខ្ញុំគិតថា ដោយក្រុមហ៊ុនមួយចំនួនមិនបានមកចុះបញ្ជីយើងត្រូវប្រើប្រាស់នូវការរៀបចំស្ថិតិសម្រាប់កំណត់នូវអត្តសញ្ញាណនៃអ្នកក្រីក្រនេះ នៅក្នុងចំណោមរោងចក្រ សហគ្រាស កសិដ្ឋានដែលប្រើប្រាស់កម្មករជាស្ត្រីនោះតែម្តង។

**សម្តេចតេជោ** ថ្លែងសង្កត់ធ្ងន់ថា ងាយស្រួលទេនិយាយពីបញ្ហាគោរពសិទ្ធស្ត្រី និង ងាយស្រួលទេពីការនិយាយពីការយកចិត្តទុកដាក់ចំពោះស្ត្រី ក៏ប៉ុន្តែប្រសិន បើគ្មានសកម្មភាពជាក់ស្តែងបម្រើឱ្យការអនុវត្តនូវកម្មវិធីនោះជាក់លាក់ទេ វានឹងគ្មានន័យអ្វីទាំងអស់ សម្រាប់ការជួបជុំនៃបុណ្យទិវានារីម្តងៗនោះឡើយ៕











# រាជរដ្ឋាភិបាលកំពុងរៀបចំច្បាប់របបសន្តិសុខសង្គម ដែលឱ្យបុគ្គលិកវិស័យឯកជន និងមន្ត្រីរាជការ មានប្រាក់សោធននិវត្តន៍ដូចគ្នា

តំណាងរាជរដ្ឋាភិបាល ដឹកនាំដោយ **លោកជំទាវ ខួន សុខា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាជាតិគាំពារសង្គម បានជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា លើសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម នារសៀលថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៩ នៅវិមានរដ្ឋសភា។





**លោកជំទាវ ខួន សុខា** បានមានប្រសាសន៍ថា បន្ទាប់ពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុនសែន** នាយករដ្ឋមន្ត្រី បានប្រកាសថា ចាប់ពីឆ្នាំ២០១៩ ទៅវិស័យឯកជននឹងមានរបបសោធននិវត្តន៍ដូចមន្ត្រីរាជការដែរ ក្រុមការងារអន្តរក្រសួង ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួមជាមួយក្រសួងផ្សេងៗទៀត បានរួមគ្នារៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម។ សេចក្តីព្រាងច្បាប់នេះមានជំពូកមួយនិយាយពីរបបសោធននិវត្តន៍។

**លោកជំទាវ** បានបន្តថា នៅក្នុងរបបសោធននិវត្តន៍នៃច្បាប់ថ្មីនេះ នឹងបញ្ចូលការដាក់ឱ្យអនុវត្តនូវរបបសោធននិវត្តន៍សម្រាប់វិស័យឯកជន និងការធ្វើកំណែទម្រង់របបសោធននិវត្តន៍មន្ត្រីរាជការដែលមានស្រាប់។ សេចក្តីព្រាងច្បាប់ថ្មី បានកំណត់ថា មន្ត្រីរាជការដែលធ្វើការបាន៣០ឆ្នាំ នឹងទទួលបានប្រាក់សោធននិវត្តន៍ប្រមាណ៦០ភាគរយ នៃប្រាក់បៀវត្សរ៍សរុប ដែលខុសពីបច្ចុប្បន្នមន្ត្រីរាជការ ចូលនិវត្តន៍ទទួលបានប្រាក់សោធននិវត្តន៍ ៨០ភាគរយនៃប្រាក់បៀវត្សរ៍មូលដ្ឋាន។

**ឯកឧត្តម ឡេង ប៉េងឡុង** បានមានប្រសាសន៍៖ ឯកភាពចំពោះគោលបំណងដែលចង់ឱ្យមានគោលការណ៍រួមគ្នារវាងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ឬជាមួយវិស័យឯកជន នៅលើចំណុចខ្លះនោះ។ ឯកឧត្តមបានបញ្ជាក់ថា កន្លងមកមានច្បាប់មួយចំនួនហើយ ដែលស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ឬវិស័យឯកជន បានអនុវត្តរួមគ្នាដូចជាច្បាប់ពន្ធដារច្បាប់ប្រព័ន្ធហិរញ្ញវត្ថុច្បាប់លទ្ធកម្ម ដូច្នេះច្បាប់របបសន្តិសុខសង្គមក៏អាចអនុវត្តបានទាំងអស់គ្នាដែរ។



**ឯកឧត្តម ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា បានកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការយកចិត្តទុកដាក់ ដំឡើងប្រាក់បៀវត្សរ៍និងការទទួលបានអត្ថប្រយោជន៍នានាជូនមន្ត្រីរាជការ កម្មករ និយោជិត ដែលធ្វើឱ្យជីវភាពពលរដ្ឋកាន់តែល្អប្រសើរឡើង។ សម្រាប់សេចក្តីព្រាងច្បាប់ថ្មី **ឯកឧត្តម** បានស្នើដល់នាយកដ្ឋានពាក់ព័ន្ធនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការសិក្សាឱ្យបានលម្អិតបន្ថែមទៀត៕





# ឆ្នាំ២០១៨ ដែលទើបកន្លងផុតទៅថ្មីៗនេះ មានកម្មករនិយោជិតជាស្ត្រីសម្រាលកូនចំនួន ៦៥ ០៥៤ នាក់ បានទទួលប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលតាមរយៈបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម បានថ្លែងបញ្ជាក់ថា៖នេះជាការផ្តល់ជូនកាដូពិសេសក្នុងការឆ្លើយតបទៅនឹងជីវភាពរស់នៅរបស់បងប្អូនកម្មករនិយោជិត ជាស្ត្រីសម្រាលកូន ដែលកើតចេញពីគោលនយោបាយជាតិគាំពារសង្គម ក្នុងការលើកកម្ពស់សេវាគាំពារសង្គម និងការលើកកម្ពស់កំណើនប្រជាជនកម្ពុជាក្នុងការដោះស្រាយនូវទុក្ខលំបាករបស់បងប្អូនកម្មករនិយោជិត។





គិតចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ ២០១៨ រហូតមកដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដែលទើបកន្លងផុតទៅថ្មីៗនេះ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម របស់រាជរដ្ឋាភិបាល ដល់កម្មករនិយោជិតជាស្ត្រីសម្រាលកូន មានចំនួន ៦៥ ០៥៤ នាក់ កូនចំនួន ៦៥ ៥៣៤ នាក់ និង ចំណាយទឹកប្រាក់អស់ជាង ២៦ពាន់លានរៀល ។

**ឯកឧត្តម ប្រតិត្ថ** បានថ្លែងបន្តថា ទាំងនេះគឺឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការយកចិត្តទុកខ្ពស់បំផុតពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំពោះសុខុមាលភាព និង ជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋកម្ពុជា។



**ឯកឧត្តម ប្រតិត្ថ** បានថ្លែងឡើងដូច្នេះ នៅក្នុងពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ចំនួន ២០៨៩ ប័ណ្ណជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងយុត្តិធម៌ កាលពីថ្ងៃពុធ ១១រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រី បុគ្គលិកក្រោមឱវាទសរុប ប្រមាណជាង ៧០នាក់ ស្ថិតនៅក្នុងសាលប្រជុំនៃក្រសួងយុត្តិធម៌ផ្ទាល់ ។

**ឯកឧត្តម ប្រតិត្ថ** បានថ្លែងបញ្ជាក់ទៀតថា៖ ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្ត ឱ្យទទួលបន្ទុកលើការងារចុះបញ្ជី កម្មករនិយោជិតក្រៅប្រព័ន្ធ ដើម្បីទទួលបានសេវាមូលនិធិសមធម៌សុខាភិបាល ដែលមកដល់បច្ចុប្បន្ននេះ បានចុះបញ្ជីសហគ្រាសចំនួន ២៣ ១៨៣ សហគ្រាស និងកម្មករនិយោជិតសរុបចំនួន ១៣៧ ៨៤៥ នាក់ ។



បច្ចុប្បន្ន ប.ស.ស បានផ្តល់តាវកាលិកផ្នែកហានិភ័យ-ការងារដល់ជនរងគ្រោះជាកម្មករនិយោជិតចំនួន ២១៦ ៣៥៧ នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិកចំនួន ១ ៦១៤ ៣៣៩ នាក់ នៃសហគ្រាសចំនួន ១២ ៦៨៨ សហគ្រាស។ ដោយឡែកសម្រាប់ផ្នែកថែទាំសុខភាព បានផ្តល់សេវាដល់កម្មករនិយោជិតចំនួន ១ ៨៥០ ៧១៩ ដង-នាក់ ក្នុងចំណោមកម្មករនិយោជិតប្រមាណជាង ១ ៦១៤ ៣៣៩ នាក់ នៃសហគ្រាសចំនួនជាង ១០ ១៥២ ៕



# ពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងកិច្ចការនារី



**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម បានថ្លែងថា គិតមកដល់ពេលនេះ ប.ស.ស បានប្រគល់ប័ណ្ណសមាជិក ប.ស.ស ជូនដល់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលជាសមាជិករបស់ខ្លួនបានចំនួនជាង ១៥ ម៉ឺននាក់ហើយ ក្នុងចំណោមសមាជិក ប.ស.ស ជាមន្ត្រីសាធារណៈ សរុបជាង ៣០ម៉ឺននាក់។





**ឯកឧត្តម ប្រតិភូ** បានថ្លែងបញ្ជាក់ថា បច្ចុប្បន្នបេឡាជាតិរបបសន្តិសុខសង្គម បានផ្តល់សេវាថែទាំសុខភាព ជូនដល់សមាជិក ប.ស.ស ជាមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានចំនួន ២៥៨ ៥១១ ដង-នាក់ នៅតាមមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស តាមរយៈការប្រើប្រាស់ប័ណ្ណសមាជិក ប.ស.ស។

**ឯកឧត្តម ប្រតិភូ** បានថ្លែងបន្តទៀតថា ប.ស.ស នឹងបន្តកិច្ចសហការក្នុងការផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ទៅដល់ក្រសួង ស្ថាប័នមួយចំនួនទៀត ដែល ប.ស.ស មិនទាន់បានធ្វើកិច្ចសហការក្នុងការផ្តល់ប័ណ្ណ សម្រាប់ការទៅទទួលសេវារបបសន្តិសុខសង្គមនៅតាមមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស។ ទាក់ទងទៅនឹងការផ្តល់ប័ណ្ណសមាជិក ប.ស.ស នេះដែរ **ឯកឧត្តម ប្រតិភូ** រាជរដ្ឋាភិបាល បានថ្លែងរំលឹកថាបច្ចុប្បន្ន  បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានពង្រីកវិសាលភាពរបស់ខ្លួនគ្របដណ្តប់ទូទាំងប្រទេសដោយ មានមន្ត្រីរាជការ និងបុគ្គលិកដែលកំពុងបម្រើការងារសរុប ១ ៣៥៩នាក់។







អនុលោមតាមប្រកាសអន្តរក្រសួងលេខ ២៩១ក.ប/ប្រ.ក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិ-សុខសង្គម និងមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព ប.ស.ស បានចុះកិច្ចព្រមព្រៀង ជាមួយមូលដ្ឋានសុខាភិបាល ចាប់ពីថ្នាក់មណ្ឌលសុខភាព រហូតដល់ថ្នាក់ជាតិចំនួន ១ ៣៣៥ មូលដ្ឋានសុខាភិបាល  នៅក្នុងនោះមានមន្ទីរពេទ្យរដ្ឋចំនួន ១ ២៩២ មូលដ្ឋានសុខាភិបាល និងមន្ទីរពេទ្យឯកជនចំនួន ៤៣មូលដ្ឋានសុខាភិបាលដើម្បីសម្រួលដល់ការផ្តល់សេវាជូនសមាជិក ប.ស.ស ឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព។





**ឯកឧត្តម ប្រតិទ្ធ** បានបន្តទៀតថា គិតចាប់ពីពេលដំណើរការដំបូងក្នុងឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ប.ស.ស បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារដល់ជនរងគ្រោះជាកម្មករនិយោជិតបានចំនួន ២១៦ ៣៥៧នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិកចំនួន ១ ៦១៤ ៣៣៩ នាក់នៃសហគ្រាសចំនួន ១២ ៦៨៨  និងសម្រាប់ផ្នែកថែទាំសុខភាពបានផ្តល់សេវាដល់កម្មករនិយោជិតចំនួន ១ ៨៥០ ៧១៩ ដងនាក់ ក្នុងចំណោមកម្មករនិយោជិតប្រមាណជាង ១ ៦១៤ ៣៣៩ នាក់ នៃសហគ្រាសប្រមាណ ១០ ១៥២ សហគ្រាស។





**ឯកឧត្តម ប្រតិទ្ធ** លើកឡើងយ៉ាងដូច្នេះ នាឱកាសពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹកនាំ មន្រ្តីរាជការ និងមន្រ្តីជាប់កិច្ចសន្យា នៃក្រសួងកិច្ចការនារី ចំនួន ៩៣៥ ប័ណ្ណ នៅទីស្តីការក្រសួងកិច្ចការនារី ក្រោមអធិបតីភាព **លោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្រ្តីក្រសួងកិច្ចការនារី និងមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ មន្រ្តីតំណាងអង្គភាព  ស្ថាប័ន  ក្រោមឱវាទ សរុបប្រមាណជាង ៣០០នាក់ នៅព្រឹកថ្ងៃអង្គារ ៣កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ៕





# ប.ស.ស ប្រគល់ប័ណ្ណសមាជិក ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៅក្រសួងធនធានទឹក និងឧតុនិយម





**ឯកឧត្តម ស៊ុំ សោភ័ណ** នាយករង បេឡាជាតិរបបសន្តិសុខសង្គម និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស នៅក្នុងពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស និងផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ជូនដល់ថ្នាក់ដឹកនាំមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាក្រសួងធនធានទឹក និងឧតុនិយម ដែលប្រព្រឹត្តទៅនៅថ្ងៃពុធ ៤កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៩ នៅក្នុងទីស្តីការក្រសួងធនធានទឹក និងឧតុនិយមផ្ទាល់ **ឯកឧត្តមប្រតិភូ** បានថ្លែងថា៖ ប.ស.ស បានចុះប្រគល់ប័ណ្ណសមាជិករបស់ខ្លួនជូនដល់មន្ត្រីសាធារណៈ បានចំនួន២២ ក្រសួងរួចមកហើយ។

ប.ស.ស នៅតែបន្តសហការជាមួយបណ្តាក្រសួងផ្សេងទៀត ក្នុងការផ្តល់ប័ណ្ណសមាជិក ប.ស.ស ជូនដល់មន្ត្រីសាធារណៈ ដែលមិនទាន់មានប័ណ្ណ ប.ស.ស សម្រាប់ទៅទទួលសេវារបបសន្តិសុខសង្គម នៅតាមមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។



**ឯកឧត្តម** នាយករង បានថ្លែងបន្តថា៖ បច្ចុប្បន្នមានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានទៅទទួលសេវាថែទាំសុខភាព នៅតាមមូលដ្ឋានសុខាភិបាលដែលជាដៃគូជាមួយ ប.ស.ស បានចំនួន ៣០ ៧២៧ ដង-នាក់ តាមរយៈការទទួលបានប័ណ្ណមាជិក ប.ស.សដ៏សំខាន់នេះ។



**ឯកឧត្តម** នាយករង បានបញ្ជាក់ថា ប័ណ្ណ សមាជិក ប.ស.ស គឺជាសមិទ្ធផលដ៏ល្អមួយ ដែលរាជរដ្ឋាភិបាលកម្ពុជាបង្កើតឡើង ដើម្បីបម្រើដល់ផលប្រយោជន៍ មន្ត្រីរាជការ និងបងប្អូនកម្មករនិយោជិត។ ប.ស.ស នឹងបន្តពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ នឹងបន្តជម្រុញការអនុវត្តផ្នែកថែទាំសុខភាព ទាំងសម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ និងខិតខំរៀបចំដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន សម្រាប់កម្មករនិយោជិត និងផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈនៅក្នុងឆ្នាំ២០១៩នេះ៕






# ប.ស.ស ផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៅអង្គភាពប្រឆាំងអំពើពុករលួយ

**ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស បានបញ្ជាក់ថា កន្លងមក ប.ស.ស បានធ្វើកិច្ចសហការតាមបណ្តាក្រសួងមួយចំនួនរួចមកហើយ ក្នុងការផ្តល់ប័ណ្ណសមាជិក ប.ស.ស ទៅដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។ នៅថ្ងៃព្រហស្បតិ៍ ៥កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩នេះ ប.ស.ស បានសហការជាមួយអង្គភាពប្រឆាំងអំពើពុករលួយ បន្តផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ជូនដល់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា ចំនួន ៤០៨ប័ណ្ណបន្ថែមទៀត នៅអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីទទួលបានសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។






**ឯកឧត្តម** នាយករង បានថ្លែងរំលឹកបន្តថា៖ តាមរយៈការអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យឯកជនប្រកបដោយជោគជ័យគួរជាទីមោទនៈ កន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្ត និងបានប្រគល់ភារកិច្ចបន្ថែមជាប្រតិបត្តិករតែមួយគត់ក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ។







**ឯកឧត្តម** នាយករង បានបញ្ជាក់ទៀតថា៖ ចាប់ពីដើមឆ្នាំ ២០១៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានដាក់ឱ្យដំណើការ នូវកញ្ចប់តាវកាលិករួមមាន៖

- សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
- សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះចំពោះករណីសង្គ្រោះបន្ទាន់ សេវាបញ្ជូនសព
- សេវាបង្ការសុខភាព។

មកដល់ពេលនេះ មានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនទៅទទួលសេវាថែទាំសុខភាពបានចំនួន ៣០ ៧២៧ ដង-នាក់ ហើយ ។



**ឯកឧត្តម អ៊ឹម ចាន់ថុល** ឧបការី នៃអង្គភាពប្រឆាំងអំពើពុករលួយ បានវាយតម្លៃថា ប័ណ្ណសមាជិក ប.ស.ស នេះគឺជាសមិទ្ធផលដ៏ល្អមួយ ដែលរាជរដ្ឋាភិបាលកម្ពុជា បង្កើតឡើងដើម្បីបម្រើដល់ផលប្រយោជន៍ មន្ត្រីរាជការនិងបងប្អូនកម្មករនិយោជិត៕



# ប.ស.ស ផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៅក្រសួងទេសចរណ៍



**ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស បានបញ្ជាក់ថា៖ កន្លងមក ប.ស.ស បានធ្វើកិច្ចសហការតាមបណ្តាក្រសួងមួយចំនួន រួចមកហើយក្នុងការផ្តល់ប័ណ្ណសមាជិក ប.ស.ស ទៅដល់មន្ត្រីរាជការ និង មន្ត្រីជាប់កិច្ចសន្យា ហើយនៅថ្ងៃចន្ទ ៩កើត ខែបុស្សឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩នេះ ប.ស.ស បានសហការជាមួយក្រសួង ទេសចរណ៍ បន្តផ្តល់ប័ណ្ណសមាជិករបស់ខ្លួនជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ចំនួន ១ ១១១ ប័ណ្ណបន្ថែមទៀត នៅក្រសួងទេសចរណ៍ដើម្បីឱ្យទទួលបានសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ច ព្រមព្រៀងជាមួយ ប.ស.ស ។





**ឯកឧត្តម** នាយករង បានថ្លែងរំលឹកបន្តទៀតថា៖ តាមរយៈការអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យឯកជនប្រកបដោយ ជោគជ័យនាពេលកន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្ត និងបានប្រគល់ភារកិច្ចបន្ថែមជាប្រតិបត្តិករតែមួយគត់ក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិ-សុខសង្គមផ្នែកហានិភ័យការងារសម្រាប់ មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និង អតីតយុទ្ធជន មានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ។

**ឯកឧត្តម** នាយករង បានបញ្ជាក់ទៀតថា៖ ចាប់ពីដើមឆ្នាំ ២០១៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានដាក់ឱ្យដំណើការ នូវកញ្ចប់តាវកាលិក រួមមាន៖

– សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

– សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ

ចំពោះករណីសង្គ្រោះបន្ទាន់ សេវាបញ្ជូនសព

– សេវាបង្ការសុខភាព ។

មកដល់ពេលនេះ មានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និង អតីតយុទ្ធជនទៅទទួលសេវាថែទាំសុខភាព បានចំនួន ៣០ ៧២៧ ដង-នាក់ ហើយ។

**ឯកឧត្តម ថោង ខុន** រដ្ឋមន្ត្រីស្តីទីក្រសួងទេសចរណ៍ បានវាយតម្លៃថា ប័ណ្ណសមាជិក ប.ស.ស នេះ គឺជាសមិទ្ធផលដ៏ល្អមួយ ដែលរាជរដ្ឋាភិបាលកម្ពុជាបង្កើតឡើង ដើម្បីបម្រើដល់ផលប្រយោជន៍ មន្ត្រីរាជការ និងបងប្អូនកម្មករនិយោជិត៕











# កិច្ចប្រជុំពិគ្រោះយោបល់ជាមួយមូលដ្ឋានសុខាភិបាលកម្រិតថ្នាក់ជាតិ ស្តីពីការកំណត់តម្លៃឱសថក្រៅពីបញ្ជីឱសថសារវន្ត សម្រាប់ការព្យាបាលជំងឺលើសឈាម សម្ពាធឈាម និងជំងឺទឹកនោមផ្អែម ជូនដល់សមាជិក ប.ស.ស

**ឯកឧត្តម ស៊ុំ សោភ័ណ** នាយករង បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបើកកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយនឹងតំណាងថ្នាក់ដឹកនាំមូលដ្ឋានសុខាភិបាលកម្រិតថ្នាក់ជាតិចំនួន ៣ នៅក្នុងរាជធានីភ្នំពេញ។ កិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ខាងលើនេះ ធ្វើឡើងនៅថ្ងៃព្រហស្បតិ៍ ១២កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ ស្ថិតនៅសាលប្រជុំធំ នៃ ប.ស.ស ដោយមានការអញ្ជើញចូលរួមពីភាគីទាំងពីរប្រមាណជាង ៤០នាក់។





**ឯកឧត្តម** នាយករង បានបញ្ជាក់ថា កិច្ចប្រជុំនេះ ផ្តោតសំខាន់អំពីការកំណត់តម្លៃឱសថក្រៅពីបញ្ជីឱសថសារវន្តសម្រាប់ព្យាបាលជំងឺលើសឈាម សម្ពាធឈាម និងជំងឺទឹកនោមផ្អែម ជូនដល់សមាជិក ប.ស.ស និងជម្រុញឱ្យមូលដ្ឋាន សុខាភិបាលទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងឯកជនទាំងអស់ ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស គប្បីយកចិត្តទុកដាក់បន្ថែមទៀតទាក់ទងទៅនិងការមកទទួលសេវាពិនិត្យ ព្យាបាលជំងឺរបស់សមាជិក ប.ស.ស ប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា។

**ឯកឧត្តម** នាយករង បានឱ្យដឹងថា កម្មករនិយោជិតមួយចំនួន នៅមិនទាន់យល់ដឹងច្បាស់ពីនីតិវិធីក្នុងការទៅទទួលសេវាពិនិត្យ និងព្យាបាលជំងឺ ដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យដែល បាន ចុះកិច្ចព្រម ព្រៀង ជាមួយ ប.ស.ស នៅឡើយទេ ដូច្នេះដើម្បីឱ្យកាន់តែមានភាពល្អប្រសើរឡើង សូមឱ្យមានការចូលរួមដោយយកចិត្តទុកដាក់បន្ថែមទៀតពីខាងមន្ទីរពេទ្យ។ បច្ចុប្បន្ន បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចុះកិច្ចព្រម ព្រៀង ជាមួយ មូល ដ្ឋាន សុខាភិបាល សាធារណៈ និងមន្ទីរពេទ្យឯកជន សរុបចំនួន ១ ៣៣៧ មូលដ្ឋានសុខាភិបាល ក្នុងនោះមានមន្ទីរពេទ្យរដ្ឋចំនួន ១ ២៩២ មូលដ្ឋានសុខាភិបាល និងមន្ទីរពេទ្យឯកជនចំនួន ៤៥ មូលដ្ឋានសុខាភិបាល ដើម្បីសម្រួលដល់ការផ្តល់សេវាជូនសមាជិក ប.ស.ស ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ទាំងនេះ គឺជាការឆ្លើយតបស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យកម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធទាំងអស់ទទួលបានសេវាគាំពារសង្គម ដើម្បីរក្សាសុខុមាលភាព និងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនកម្មករនិយោជិតឱ្យកាន់តែប្រសើរឡើង៕









# កិច្ច ប្រជុំពិភាក្សាលើការផ្តល់សេវា និងការទូទាត់ថ្លៃសេវា ជាមួយមន្ទីរពេទ្យឯកជន ដែលជាដៃគូជាមួយ ប.ស.ស

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្នុងកិច្ចប្រជុំពិភាក្សាលើការផ្តល់សេវា និងការទូទាត់ថ្លៃសេវា ជាមួយមន្ទីរពេទ្យដែលជាដៃគូជាមួយ ប.ស.ស បានថ្លែងថាៈ កិច្ចប្រជុំពិភាក្សានេះ គឺដើម្បីពង្រឹងគុណភាពការផ្តល់សេវាជូនសមាជិក ប.ស.ស ឱ្យកាន់តែល្អប្រសើរនិងចូលរួមដោះស្រាយរាល់បញ្ហាប្រឈមនានា ដែលកើតមានឡើងក្នុងពេលអនុវត្តការងារកន្លងមក។





**ឯកឧត្តម ប្រតិភូ** បានថ្លែងបន្តថាៈ វេទិកាដ៏មានសារៈសំខាន់នេះ គឺជាឱកាសមួយសម្រាប់ឱ្យភាគី ប.ស.ស និងមូលដ្ឋានសុខាភិបាលឯកជនដែលជាដៃគូ បានពិភាក្សាផ្តល់យោបល់ប្រកបដោយន័យស្ថាបនា លើបញ្ហាប្រឈម និងស្វែងរកដំណោះស្រាយ កាន់តែល្អប្រសើរ សមស្របទៅនឹងបរិយាកាសសេដ្ឋកិច្ចនិងសង្គមកិច្ចប្រទេសកម្ពុជាបច្ចុប្បន្នដែលកំពុងតែមានវឌ្ឍនភាពឥតឈប់ឈរ ព្រមទាំងមានការគាំទ្រយ៉ាងពេញទំហឹងពីពលរដ្ឋរបស់ខ្លួនផងដែរ។

**ឯកឧត្តម ប្រតិភូ** បានបញ្ជាក់ទៀតថា បច្ចុប្បន្ន ប.ស.ស បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលចាប់ពីថ្នាក់មណ្ឌលសុខភាព រហូតដល់ថ្នាក់ជាតិ សរុបចំនួន ១ ៣៣៧ មូលដ្ឋានសុខាភិបាល នៅក្នុងនោះមានមន្ទីរពេទ្យរដ្ឋចំនួន ១ ២៩២ និងមន្ទីរពេទ្យឯកជនចំនួន ៤៥។



**ឯកឧត្តម ប្រតិភូ** បានបន្តទៀតថា ការកើនឡើងនៃមន្ទីរពេទ្យឯកជន គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងការជួយសម្រួលសេវាព្យាបាលដល់មន្ទីរពេទ្យរដ្ឋបានយ៉ាងច្រើនក្នុងការផ្តល់សេវាជូនបងប្អូនកម្មករនិយោជិត ដែលជាសមាជិក ប.ស.ស គិតរហូតមកដល់ពេលនេះ ប.ស.ស បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារ ដល់ជនរងគ្រោះជាកម្មករនិយោជិតចំនួន ២១៦ ៣៥៧នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិកចំនួន ១ ៦១៤ ៣៣៩នាក់ នៃសហគ្រាសចំនួន ១២ ៦៨៨ សហគ្រាស។ ដោយឡែកសម្រាប់ផ្នែកថែទាំសុខភាព បានផ្តល់សេវា ដល់កម្មករនិយោជិតចំនួន ១ ៨៥០ ៧១៩ដង-នាក់ ក្នុងចំណោមកម្មករនិយោជិតប្រមាណជា ១ ៦១៤ ៣៣៩នាក់ នៃសហគ្រាសចំនួន ១០ ១៥២ សហគ្រាស ។



**ឯកឧត្តម ប្រតិភូ** បានថ្លែងបន្តទៀតថា ប.ស.ស នឹងព្យាយាមដោះស្រាយរាល់បញ្ហាប្រឈមក្នុងការទៅទទួលសេវារបបសន្តិសុខសង្គម របស់សមាជិក ប.ស.ស និងដោះស្រាយរាល់បញ្ហារបស់និយោជក ម្ចាស់សហគ្រាស/គ្រឹះស្ថាន និងជាពិសេសធ្វើការដោះស្រាយឱ្យទាន់ពេលវេលាក្នុងការផ្តល់សេវាជូនកម្មករនិយោជិត។ ការលើកឡើងរបស់ **ឯកឧត្តម** ប្រតិភូ ត្រូវបានធ្វើឡើងក្នុងកិច្ចប្រជុំពិភាក្សាលើការផ្តល់សេវា និងការទូទាត់ថ្លៃសេវា ជាមួយមន្ទីរពេទ្យឯកជន ដែលជាដៃគូជាមួយ ប.ស.ស នៅថ្ងៃអង្គារ ២រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ដោយមានការចូលរួមពីតំណាងមន្ទីរពេទ្យដៃគូ និងថ្នាក់ដឹកនាំ មន្ត្រីក្រោមឱវាទសរុបប្រមាណជា ៧០នាក់ នៅសាលប្រជុំធំ នៃស្នាក់ការកណ្តាលបេឡាជាតិរបបសន្តិសុខសង្គម ៕









# ប.ស.ស ផ្តល់ប័ណ្ណ សមាជិករបស់ខ្លួនចំនួន ១២ ២៦០ ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃក្រសួងមហាផ្ទៃ

យោងតាមរបាយការណ៍របស់តំណាងថ្នាក់ដឹកនាំនៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដែលបានលើកឡើងក្នុងពិធីប្រគល់-ទទួលប័ណ្ណ សមាជិក ប.ស.ស នៅក្រសួងមហាផ្ទៃ នៅថ្ងៃសុក្រ ១២រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១ កុម្ភៈ ឆ្នាំ២០១៩ នេះ បានឱ្យដឹងថា៖ ប.ស.ស បានធ្វើកិច្ចសហការតាមបណ្តាក្រសួង ស្ថាប័ន មួយចំនួនរួចមកហើយ ក្នុងការផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដោយឡែកប័ណ្ណសមាជិក ប.ស.ស ចំនួន ១២ ២៦០ប័ណ្ណ ត្រូវបានផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៅក្រសួងមហាផ្ទៃថែមទៀត ដើម្បីទទួលបានសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដោយឥតបង់ថ្លៃ។ តាមរយៈការអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យឯកជនប្រកបដោយជោគជ័យគួរជាទីមោទនកន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្ត និងបានប្រគល់ភារកិច្ចបន្ថែមជាប្រតិបត្តិករតែមួយគត់ក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧។






ប.ស.ស បានចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន សរុបចំនួន ៣១៧ ៥០៩នាក់ និងបានទៅទទួលសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស បានចំនួន ៣០ ៧២៧ ដង-នាក់ ។គួរបញ្ជាក់ថា ចាប់ពីដើមឆ្នាំ ២០១៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានដាក់ឱ្យដំណើការ នូវកញ្ចប់តាវកាលិករួមមានៈ

– សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
– សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ
ចំពោះករណីសង្គ្រោះបន្ទាន់ សេវាបញ្ជូនសព
– សេវាបង្ការសុខភាព។





គិតចាប់ពីពេលដំណើរការដំបូងក្នុងឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន ប.ស.ស បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារដល់ជនរងគ្រោះជាកម្មករនិយោជិតបានចំនួន ២១៧ ៩៣១ នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិកចំនួន ១ ៦៣៧ ៣៤០នាក់ នៃសហគ្រាសចំនួនជាង ១២ ៥៥៤ សហគ្រាស និងសម្រាប់ផ្នែកថែទាំសុខភាព បានផ្តល់សេវាដល់កម្មករនិយោជិតចំនួន ២ ០៣០ ៣០៧ ដង-នាក់ ក្នុងចំណោមកម្មករនិយោជិតប្រមាណជាង ១ ៦១៤ ៣៣៩ នាក់ នៃសហគ្រាសចំនួនជាង ១០ ១៥២ សហគ្រាស ។ ទាំងអស់នេះ គឺបង្ហាញយ៉ាងច្បាស់ពីការយកចិត្តទុកដាក់ខ្ពស់បំផុត ពីសំណាក់ប្រមុខរាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទៅលើសុខុមាលភាព និងជីវៈភាពរស់នៅ របស់បងប្អូនប្រជាពលរដ្ឋកម្មករនិយោជិត និងមន្ត្រីសាធារណៈទាំងអស់ដែលជានិយោជិតរបស់រដ្ឋ ៕





# មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់ កុំព្រួយបារម្ភណ៍ រឿងលុយថ្លៃសេវាព្យាបាលនៅពេលមានបញ្ហាសុខភាព



**ឯកឧត្តម ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានអញ្ជើញចូលរួម នៅក្នុងពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ចំនួន ១៧២៧ ប័ណ្ណ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងព័ត៌មាន នៅថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩នេះ ដែលមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីតំណាងក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទសរុបប្រមាណជាង ២០០នាក់ នៅទីស្តីការក្រសួងព័ត៌មាន។





**ឯកឧត្តម** រដ្ឋមន្ត្រី បានមានប្រសាសន៍ថា ទាំងមន្ត្រីរាជការ និងបងប្អូនកម្មករនិយោជិតដែលជាសមាជិក ប.ស.ស ទាំងអស់នឹងលែងបារម្ភណ៍នៅពេលចាស់ជរាបម្រើការលែងកើត ព្រោះ ប.ស.ស បានរៀបចំរបបផ្នែកប្រាក់សោធន(ប្រាក់-រ៉ឺត្រែត) ជូនដល់ពួកគាត់ផងដែល ជាពិសេសមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់ កុំព្រួយបារម្ភណ៍រឿងលុយថ្លៃសេវាព្យាបាលនៅពេលមានបញ្ហាសុខភាព ព្រោះបេឡាជាតិរបប-សន្តិសុខសង្គម ប.ស.ស ចេញថ្លៃសេវាព្យាបាល។ ក្នុងឱកាសនោះ **ឯកឧត្តម** រដ្ឋមន្ត្រី បានកោតសរសើរបេឡាជាតិរបបសន្តិ-សុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។

**ឯកឧត្តមបណ្ឌិត ស៊ុំ សោភ័ណ** នាយករង ប.ស.ស និងជាតំណាង **ឯកឧត្តម អ៊ិត សមហិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយក ប.ស.ស បានបញ្ជាក់ថា៖ របបសន្តិសុខសង្គមគឺជាសមិទ្ធផលថ្មីមួយរបស់រាជរដ្ឋាភិបាលដែលពីមុនកម្ពុជាមិនធ្លាប់មាននោះទេ។ នេះគឺជាការយកចិត្តទុកដាក់ខ្ពស់បំផុតពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះសុខទុក្ខ និងជីវភាពរស់នៅ របស់មន្ត្រីរាជការរួមទាំងបងប្អូនជាកម្មករនិយោជិតរបស់យើងផងដែរ៕







# ប.ស.ស ផ្តល់ប័ណ្ណសមាជិករបស់ខ្លួនចំនួន១០៦៨ ប័ណ្ណ ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម





**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម បានបញ្ជាក់ថា កន្លងមក ប.ស.ស បានធ្វើកិច្ចសហការជាមួយក្រសួងមួយចំនួនរួចមកហើយ ក្នុងការផ្តល់ប័ណ្ណសមាជិក ប.ស.ស ដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា បន្ទាប់មក ប.ស.ស បានសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្មបន្តទៀត ក្នុងការផ្តល់ប័ណ្ណសមាជិករបស់ខ្លួន ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ចំនួន ១ ០៦៨ប័ណ្ណ ដើម្បីឱ្យពួកគាត់ទទួលបានសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។



**ឯកឧត្តម ប្រតិភូ** បានបន្តថា ចាប់ពីឆ្នាំ២០០៨ រហូតដល់បច្ចុប្បន្ន ប.ស.ស បានពង្រីកវិសាលភាព គ្រប់ដណ្តប់ទូទាំងប្រទេស ដោយមានមន្ត្រីរាជការ និងបុគ្គលិកកំពុងបម្រើការងារសរុបចំនួន ១ ៣៥៩នាក់ ក្នុងនោះមានមន្ត្រីរាជការចំនួន ២២៣នាក់ និងបុគ្គលិកជាប់កិច្ចសន្យាចំនួន១ ១៣៦នាក់។

**ឯកឧត្តម ប្រតិត្ត** បានថ្លែងរំលឹកបន្តទៀតថា តាមរយៈការអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យឯកជនប្រកបដោយជោគជ័យគួរជាទី មោទនៈ កន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្ត និងបានប្រគល់ភារកិច្ចបន្ថែម ជាប្រតិបត្តិករតែមួយគត់ ក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់ មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន ដែលមានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧។



នៅដើមឆ្នាំ២០១៨ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានដាក់ឱ្យដំណើរការ នូវកញ្ចប់តាវកាលិករួមមាន៖

-សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

-សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ ចំពោះករណីសង្គ្រោះបន្ទាន់ និងសេវាបញ្ជូនសព

-សេវាបង្ការសុខភាព។



រហូតមកដល់ពេលនេះ ប.ស.ស បានចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន សរុបចំនួន ៣១៤ ០៧៦នាក់ (មន្ត្រីរាជការចំនួន ២០៤ ០៨៤នាក់ អតីតមន្ត្រីរាជការចំនួន ៥៥ ២២២នាក់ អតីតយុទ្ធជនចំនួន ៥៤ ៧៧០នាក់) និងមានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនទៅទទួលសេវាថែទាំសុខភាពបានចំនួន ២២ ០០១ដង-នាក់។





**ឯកឧត្តម ប្រតិត្ន** លើកឡើងបែបនេះ ក្នុងពិធីប្រគល់ទទួលប័ណ្ណ សមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹកនាំមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំនួន១០៦៨ប័ណ្ណ នៅសាលប្រជុំទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រោមអធិបតីភាព **ឯកឧត្តម គឹម ទូច** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ព្រមទាំងមានវត្តមានចូលរួម ពីថ្នាក់ដឹកនាំ មន្ត្រីតំណាងអង្គភាព ស្ថាប័ន ក្រោមឱវាទសរុបប្រមាណជិត ១០០នាក់ នៅថ្ងៃចន្ទ ៩កើត ខែមិគសិរ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ៕



**ឯកឧត្តម ប្រតិត្ន** បានបន្តថា ប.ស.ស នឹងបន្តពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងបន្តជម្រុញការអនុវត្ត ផ្នែកថែទាំសុខភាពទាំងសម្រាប់កម្មករនិយោជិតនិងមន្ត្រីសាធារណៈនិងខិតខំរៀបចំដាក់ឱ្យដំណើរការផ្នែកប្រាក់សោធនសម្រាប់កម្មករ និយោជិត និងផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនៅឆ្នាំ២០១៩។ នេះសបញ្ជាក់ពីការយកចិត្តទុកដាក់បំផុត ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិត ដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់ មន្ត្រីសាធារណៈទាំងអស់ដែលជានិយោជិតរបស់រដ្ឋ។





# ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល ប្រមាណជាង ២៥ពាន់លានរៀល បានបើកផ្តល់ជូនកម្មការិនីសម្រាលកូនជាសមាជិក ប.ស.ស តាមរយៈ បេឡាជាតិរបបសន្តិសុខសង្គម

គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ រហូតមកដល់ត្រឹមថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ នេះ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម របស់រាជរដ្ឋាភិបាល ដល់កម្មករនិយោជិតជាស្ត្រីសម្រាលកូនមានចំនួន ៦៣ ៦៧៧ នាក់ កូនចំនួន ៦៤ ១៤៧ នាក់ និងចំណាយទឹកប្រាក់អស់ជាង ២៥ពាន់លានរៀល តាមរយៈបេឡាជាតិរបបសន្តិសុខសង្គម។





**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម បានថ្លែងបញ្ជាក់ទៀតថា នេះបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់បំផុត ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងបងប្អូនកម្មករនិយោជិត តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានបេឡាជាតិរបបសន្តិសុខ-សង្គម (ប.ស.ស) ជាសេនាធិការ ។

**ឯកឧត្តមប្រតិភូ** បានថ្លែងបន្តថា ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្តឱ្យទទួលបន្ទុកលើការងារចុះបញ្ជីកម្មករ និយោជិតក្រៅប្រព័ន្ធ ដើម្បីទទួលបានសេវាមូលនិធិសមធម៌សុខាភិបាល ដែលមកដល់បច្ចុប្បន្ននេះ បានចុះបញ្ជីសហគ្រាស ចំនួន ២៣ ១៨៣ សហគ្រាស និងកម្មករនិយោជិតសរុបចំនួន ១៣៧ ៨៤៥ ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាសាធារណៈសម្រេចផ្តល់ប្រាក់ឧបត្ថម្ភ ដល់កម្មការិនីដែលទើបសម្រាលកូនទាំងក្នុង និងក្រៅប្រព័ន្ធ ឱ្យទទួលបានគោលរបបប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះ ៖

- សម្រាលបានកូនម្នាក់ ទទួលបាន ៤០ម៉ឺនរៀល
- សម្រាលបានកូនភ្លោះពីរ ទទួលបាន ៨០ម៉ឺនរៀល
- សម្រាលបានកូនភ្លោះបី ទទួលបាន ១លាន ២០ម៉ឺនរៀល

ដែលត្រូវបានបើកផ្តល់ជូន តាមរយៈបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។



**ឯកឧត្តមប្រតិភូ** បានថ្លែងបន្ថែមទៀតថាការផ្តល់ជូនកាដូពិសេសនេះ គឺដើម្បីឆ្លើយតបទៅនឹងជីវភាពរបស់បងប្អូនកម្មករ និយោជិត ដែលខ្វះខាតក្នុងអំឡុងពេលសម្រាលកូន និងជាគោលនយោបាយជាតិគាំពារសង្គម ក្នុងការលើកកម្ពស់សេវាគាំពារសង្គម និងការលើកកម្ពស់កំណើនប្រជាជនកម្ពុជាព្រមទាំងរួមចំណែកក្នុងការដោះស្រាយនូវទុក្ខលំបាក របស់បងប្អូនកម្មករនិយោជិត។គោលនយោបាយថ្មីនៃការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមនេះ ត្រូវបានអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ មកនិងមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់បងប្អូនជាកម្មករនិយោជិត ជាពិសេសបងប្អូន កម្មការិនីជាស្ត្រីសម្រាលកូន ។





**ឯកឧត្តមប្រតិភូ** បានថ្លែងឡើងបែបនេះ នៅក្នុងពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ចំនួន ១ ១៦០ប័ណ្ណជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នៅថ្ងៃអង្គារ ៣រោច ខែមិគសិរ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ក្រោមអធិបតីភាព **ឯកឧត្តម ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីតំណាង អង្គភាព ស្ថាប័ន ក្រោមឱវាទសរុបប្រមាណជាង ១០០នាក់ ស្ថិតនៅក្នុង សាលប្រជុំនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ឯកឧត្តម ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានលើកឡើងថា របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនគឺជាគោលនយោបាយដ៏ល្អមួយក្នុងការឆ្លើយតបទៅនឹងការរក្សាសុខុមាលភាព និងលើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីរាជការ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនឱ្យកាន់តែល្អប្រសើរឡើង៕

# បេឡាជាតិរបបសន្តិសុខសង្គម ប្រគល់ប័ណ្ណសមាជិករបស់ខ្លួនជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ




បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានសហការជាមួយក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ បន្តផ្តល់ប័ណ្ណសមាជិករបស់ខ្លួនចំនួន ៤២៨ ប័ណ្ណ ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដើម្បីទទួលបានសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។





**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម បានថ្លែងបញ្ជាក់ថា តាមរយៈការអនុវត្តរបបសន្តិសុខសង្គម សម្រាប់វិស័យឯកជនប្រកបដោយជោគជ័យគួរជាទីមោទនៈ កន្លងមក ប.ស.ស ត្រូវបានរាជរដ្ឋាភិបាលផ្តល់ទំនុកចិត្ត និងបានប្រគល់ភារកិច្ចបន្ថែម ជាប្រតិបត្តិករតែមួយគត់ ក្នុងការគ្រប់គ្រងនិងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ

អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលមានបញ្ញត្តិនៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ។ រហូតមកដល់ពេលនេះ ប.ស.ស បានចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន សរុបចំនួន ៣១៤ ០៧៦នាក់ (មន្ត្រីរាជការចំនួន ២០៤ ០៨៤នាក់ អតីតមន្ត្រីរាជការចំនួន ៥៥ ២២២នាក់ អតីតយុទ្ធជនចំនួន ៥៤ ៧៧០នាក់) និងមានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួលសេវាថែទាំសុខភាពបានចំនួន ២៥៨ ១១១ដង-នាក់។







**ឯកឧត្តមប្រតិភូ** បានថ្លែងបន្តថា ប.ស.ស នឹងបន្តពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនិងបន្តជម្រុញការអនុវត្តផ្នែកថែទាំសុខភាពទាំងសម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ និងខិតខំរៀបចំដាក់ឱ្យដំណើរការផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិត និងផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនៅឆ្នាំ ២០១៩ ។ ការថ្លែងឡើងរបស់ **ឯកឧត្តមប្រតិភូ** ត្រូវបានធ្វើឡើងក្នុងពិធីប្រគល់-ទទួលប័ណ្ណ សមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹកនាំមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅសាលប្រជុំទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ថ្នាក់ដឹកនាំ និងមន្ត្រីតំណាង អង្គភាព ស្ថាប័នក្រោមឱវាទ សរុបប្រមាណជាង ៣០០នាក់ នៅថ្ងៃពុធ ៤រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ៕





# ពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងអភិវឌ្ឍន៍ជនបទ

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយក បេឡជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានថ្លែងថា សមាជិក ប.ស.ស ជាមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួលសេវាថែទាំសុខភាព បានចំនួន ២៥៨ ៥១១ ដង-នាក់ហើយ តាមរយៈប័ណ្ណសមាជិក ប.ស.ស គិតរហូតមកដល់ពេលនេះ។







**ឯកឧត្តម ប្រតិភូ** បានថ្លែងឡើងដូច្នេះ ក្នុងពិធីប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ចំនួន ១៧១៩ ប័ណ្ណ និងផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងអភិវឌ្ឍន៍ជនបទ នាថ្ងៃសុក្រ ៦រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ នៅសាលប្រជុំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

**ឯកឧត្តម ប្រតិភូ** បានបញ្ជាក់បន្ថែមថា បច្ចុប្បន្ននេះ ប.ស.ស មានសមាជិក ជាមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន សរុបចំនួន ៣១៤ ០៧៦ នាក់ ដែលក្នុងនោះ មានមន្ត្រីរាជការចំនួន ២០៤ ០៨៤ នាក់ អតីតមន្ត្រីរាជការ ចំនួន ៥៥ ២២២ នាក់ និងអតីតយុទ្ធជនចំនួន ៥៤ ៧៧០ នាក់។









**ឯកឧត្តម ប្រតិភូ** បានថ្លែងបន្តទៀតថា ប.ស.ស នឹងបន្តពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនិងបន្តជម្រុញការអនុវត្តផ្នែកថែទាំសុខភាពទាំងសម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ និងខិតខំរៀបចំដាក់ឱ្យដំណើរការផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិត និងផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនៅឆ្នាំ២០១៩។



# ឆ្នាំ២០១៨ ប.ស.ស ទទួលបានពានរង្វាន់ ស្តីពីការ ទទួលស្គាល់អង្គភាពការងារផ្ញើមរបស់អាស៊ាន ខាងវិស័យសន្តិសុខសង្គម




តាមរយៈការអនុវត្តរបបសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព ក្នុងឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបាន ពានរង្វាន់ ស្តីពីការទទួលស្គាល់អង្គភាពការងារផ្ញើមរបស់អាស៊ាន ខាងវិស័យសន្តិសុខសង្គមលើកិច្ចដំណើរការផ្តល់សេវាល្អខាងផ្នែក ថែទាំសុខភាព ។





ការទទួលបានពានរង្វាន់ ស្តីពីការទទួលស្គាល់អង្គភាពការងារផ្ញើមរបស់អាស៊ាន ខាងវិស័យសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាពខ្ពស់ ពីសមាគមសន្តិសុខសង្គមអាស៊ានខាងលើនេះ ត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសមាគមសន្តិសុខសង្គមអាស៊ានលើកទី៣៥ ក្រោមប្រធានបទ " បដិវត្តន៍ផ្នែកឧស្សាហកម្មលើកទី៤ និងការអភិវឌ្ឍន៍វិស័យសន្តិសុខ-សង្គមអាស៊ាន " កាលពីថ្ងៃទី១៨-២០ ខែកញ្ញា ឆ្នាំ២០១៨ នៅប្រទេសវៀតណាម ។

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានថ្លែងបន្តថា ប.ស.ស នឹងបន្តពង្រឹង និងពង្រីកការអនុវត្ត របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងបន្តជម្រុញការ អនុវត្តផ្នែកថែទាំសុខភាពថែមទៀត ទាំងសម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ ព្រមទាំងខិតខំរៀបចំដាក់ ឱ្យដំណើរការ ផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិត និងផ្នែកហានិភ័យ ការងារសម្រាប់មន្ត្រីសាធារណៈផងដែរ នៅឆ្នាំ២០១៩។







ប.ស.ស មានសមាជិក ជាមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ចំនួនជាង ៣០ម៉ឺននាក់ ដែលក្នុងនោះ មានមន្ត្រីរាជការចំនួន ២០៤ ០៨៤ នាក់ អតីតមន្ត្រីរាជការចំនួន ៥៥ ២២២ នាក់ និងអតីតយុទ្ធជនសរុបចំនួន ៥៤ ៧៧០ នាក់។



បច្ចុប្បន្ន សមាជិក ប.ស.ស ជាមន្ត្រីរាជការ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានទៅទទួលសេវាថែទាំសុខភាព ចំនួន ២៥៨ ៥១១ ដង-នាក់ នៅតាមមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។




**ឯកឧត្តម ប្រតិភូ** ថ្លែងឡើងបែបនេះ នៅក្នុងពិធី ប្រគល់-ទទួលប័ណ្ណសមាជិក ប.ស.ស ចំនួន ១១៤ ៥៤៧ ប័ណ្ណ និងផ្សព្វផ្សាយអំពីគោលនយោបាយ នៃការអនុវត្តរបបសន្តិសុខសង្គម ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃក្រសួងអប់រំយុវជន និងកីឡា ដែលមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការតំណាង អង្គភាព ស្ថាប័ន ក្រោមឱវាទ សរុបប្រមាណជាង ៥០០នាក់ នៅក្នុងសាលប្រជុំនៃវិទ្យាស្ថានជាតិអប់រំនាថ្ងៃចន្ទ ៩រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៨ ។

**ឯកឧត្តម ប្រតិន្ទ** បានថ្លែងបន្តទៀតថា ទាំងនេះបង្ហាញពីការយកចិត្តទុកដាក់បំផុត ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់មន្ត្រីសាធារណៈទាំងអស់ដែលជា និយោជិតរបស់រដ្ឋ។







សូមបញ្ជាក់ថា៖ កន្លងមក ប.ស.ស ធ្លាប់បានទទួលវិញ្ញាបនបត្រ ចំនួន ០២លើករួចមកហើយ ដែលលើកទី០១ ទទួលបានវិញ្ញាបនបត្រអង្គភាពឆ្នើមក្នុងការអនុវត្តរបបសន្តិសុខ-សង្គមផ្នែកហានិភ័យការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) កាលពីថ្ងៃទី១០ ១១ ខែកញ្ញា ឆ្នាំ២០១៥ នៅប្រទេសសិង្ហបុរី នាកិច្ចប្រជុំក្រុមប្រឹក្សាភិបាល (ASSA) លើកទី៣២។ លើកទី០២ ទទួលបានវិញ្ញាបនបត្រ ស្តីពីការទទួលស្គាល់អង្គភាពការងារឆ្នើមរបស់អាស៊ាន ខាងវិស័យសន្តិសុខសង្គម លើកិច្ចដំណើរការគ្រប់ដណ្តប់ផ្នែកថែទាំសុខភាពប្រកបដោយប្រសិទ្ធភាពខ្ពស់ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦ ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) នៅប្រទេសហ្វីលីពីន ៕



# កិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយស្តីពីការអនុវត្តរបបសន្តិសុខសង្គម និងប្រគល់ប័ណ្ណសមាជិក ប.ស.ស ជូនដល់មន្ត្រីរាជការសាលាខេត្ត ក្រុង ស្រុក នៃខេត្តស្វាយរៀង



ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩បានសហការជាមួយរដ្ឋបាលសាលាខេត្តស្វាយរៀង រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ដល់មន្ត្រីរាជការសាលាខេត្ត ក្រុង ស្រុក នៃខេត្តស្វាយរៀង។កិច្ចប្រជុំផ្សព្វផ្សាយខាងលើនេះ ធ្វើឡើងក្រោមសហអធិបតីភាព **ឯកឧត្តម ម៉ែន វិបុល** អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ និងតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស ព្រមទាំងមានការចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងមន្ទីរ អង្គភាព និងស្ថានប័នពាក់ព័ន្ធនានា សរុបប្រមាណជាង ៨០នាក់។





ក្នុងឱកាសជាមួយគ្នានេះផង ដែរ ប.ស.ស ក៏បានប្រគល់ប័ណ្ណសមាជិករបស់ខ្លួន សរុបចំនួន ៣៥២ប័ណ្ណ ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាដែលកំពុងបម្រើការនៅសាលាខេត្តស្វាយរៀង ដើម្បីទទួលបានសេវាថែទាំសុខភាពនៅតាមមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដោយឥតបង់ថ្លៃរួមទាំងអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀតដែល ប.ស.ស បានផ្តល់ជូន ។

គួរបញ្ជាក់ផងដែរថា តាំងពីដំណាក់កាលដំបូងនៃការស្តារឡើងវិញនូវសេដ្ឋកិច្ចជាតិ រហូតមកដល់បច្ចុប្បន្នរាជរដ្ឋាភិបាល តែងតែបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្ពស់ទៅលើសកម្មភាពគាំពារសង្គមនានាក្នុងគោលបំណងកសាងធនធានមនុស្សនិងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋគ្រប់ៗរូបនិងការដាក់ឱ្យដំណើរការនូវប្រព័ន្ធទ្រទ្រង់ផ្នែកគោលនយោបាយសង្គមកិច្ចជាច្រើន។ ជាក់ស្តែងនៅក្នុងអាណត្តិរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភាកន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥) ដែលក្របខ័ណ្ឌគោលនយោបាយនេះ គឺជាផែនទីបង្ហាញផ្លូវរយៈពេលវែង ប្រព័ន្ធគាំពារសង្គមដែលផ្តោតលើ សសរស្តម្ភ សំខាន់ៗចំនួនពីរគឺៈ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ៕










# គណៈប្រតិភូក្រសួងការងារ នៃសាធារណរដ្ឋកេនយ៉ា មកបំពេញទស្សនកិច្ចសិក្សាស្វែងយល់អំពីការផ្តល់សេវាសន្តិសុខសង្គម របស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៅកម្ពុជា

លោក Jillo Abdul Bahari Ali អនុរដ្ឋមន្ត្រី នៃក្រសួងការងារ និងការគាំពារសង្គម នៃសាធារណរដ្ឋកេនយ៉ា បានថ្លែងថា៖ សាធារណរដ្ឋកេនយ៉ា ជាប្រទេសមួយដែលស្ថិតនៅទ្វីបអាហ្វ្រិក ប៉ែកខាងកើតដែលមានផ្ទៃដីសរុប ៥៨០,៣៦៧ គីឡូម៉ែត្រការ៉េ និងមានប្រជាជនសរុប ៤៩.៧ លាននាក់ (គិតត្រឹមឆ្នាំ២០១៧)។ កំណើនសេដ្ឋកិច្ចនៅប្រទេសមួយនេះ ជាមធ្យមក្នុងរង្វង់ ៧% ជាមួយ GDP សម្រាប់មនុស្សម្នាក់ ១,៥០៧ ដុល្លារសហរដ្ឋអាមេរិក។ កាលពីឆ្នាំ ២០១៦ ប្រទេសនេះទើបបានបង្កើតអាជ្ញាធរជាតិការងារ ហើយពុំទាន់មានដំណើរការពេញលេញនៅឡើយទេ និងកំពុងសិក្សាស្វែងយល់បន្ថែមពីបណ្តាប្រទេសនានាដែលក្នុងនោះមានកម្ពុជាយើងផងដែរ។



លោក Jillo Abdul Bahari Ali បានបន្តថា ៖ លោកមានការចាប់អារម្មណ៍និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធិផលការងាររបស់បេឡាជាតិរបបសន្តិសុខសង្គម នៅកម្ពុជា ដែលមានបទពិសោធន៍លើចំណុចល្អៗ សំខាន់ៗជាច្រើន ដូចជា ដំណើរការផ្តល់សេវារបបសន្តិសុខសង្គម លើផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន ជូនដល់បងប្អូនកម្មករនិយោជិត និងនីតិវិធីនៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន នីតិវិធីនៃការបង់ភាគទានមក ប.ស.ស និងស្វែងយល់ពីការបង្កើត និង គោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងាររបស់កម្ពុជា ស្របពេលដែលប្រទេសកេនយ៉ា ទើបបង្កើតនូវអាជ្ញាធរជាតិការងារ កាលពីឆ្នាំ២០១៦ កន្លងទៅ ។

សូមបញ្ជាក់ថា៖ ដោយមានការអនុញ្ញាតពី **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស បានចាត់ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ នៃ ប.ស.ស ដឹកនាំក្រុមការងារជួបបំពេញការងារជាមួយគណៈប្រតិភូអាជ្ញាធរជាតិការងារនៃសាធារណរដ្ឋកេនយ៉ា នៅសាលប្រជុំធំ នៃបេឡាជាតិរបបសន្តិ-សុខសង្គម (ប.ស.ស) នៅថ្ងៃពុធ ១កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ បន្ទាប់ពីគណៈប្រតិភូនេះ បានជួបពិភាក្សាការងារជាមួយ **ឯកឧត្តម បណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៕







# សកម្មភាពកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការអនុវត្តរបបសន្តិសុខសង្គម ជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៅតាមបណ្តារដ្ឋបាលខេត្ត នានា

⁕នាថ្ងៃព្រហស្បតិ៍ ០៩រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយរដ្ឋបាលខេត្តព្រៃវែង បានរៀបចំពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយស្តីពីការអនុវត្តរបបសន្តិសុខសង្គម និងផ្តល់ប័ណ្ណសមាជិក ប.ស.ស ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃរដ្ឋបាលខេត្តព្រៃវែង ដោយមានអ្នកចូលរួមប្រមាណជាង ១០០នាក់ ។ កិច្ចប្រជុំផ្សព្វផ្សាយនេះប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ចាន់ ថា** អភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែង **ឯកឧត្តម ប៉ែន នរៈឧុធ** នាយករងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) និងជាតំណាង**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស៕











⁕នាថ្ងៃពុធ ៨រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមការងារ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយរដ្ឋបាលខេត្តកំពត បានរៀបចំពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយស្តីពីការអនុវត្តរបបសន្តិសុខសង្គម និងប័ណ្ណសមាជិក ប.ស.ស ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃរដ្ឋបាលខេត្តកំពតដោយមានអ្នកចូលរួមប្រមាណជា ២០០នាក់ ។ កិច្ចប្រជុំនេះផ្សព្វផ្សាយនេះក្រោមអធិបតីភាព **ឯកឧត្តម ជាវ តាយ** អភិបាលនៃគណៈអភិបាលខេត្តកំពត និង**លោក សុក ម៉ូរ៉ា** ប្រធានការិយាល័យតាវកាលិក នៃ ប.ស.ស ក្នុងឱកាសនោះបាន ប្រគល់ប័ណ្ណសមាជិករបស់ខ្លួន ដល់មន្ត្រីរាជការសាលាខេត្ត/ក្រុង/ស្រុក ចំនួន ៤១៦ប័ណ្ណ៕



✵នាថ្ងៃចន្ទ ៦រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមការងារ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយរដ្ឋបាលខេត្តបាត់ដំបង បានរៀបចំពិធីប្រជុំផ្សព្វផ្សាយគោលនយោបាយស្តីពីការអនុវត្តរបបសន្តិសុខសង្គម ដល់និយោជក ម្ចាស់គ្រឹះស្ថាន សហគ្រាស មន្ទីរ ស្ថាប័ន និងជនរងគ្រោះដោយមានអ្នកចូលរួមប្រមាណជាង ១៥០នាក់។ កិច្ចប្រជុំនេះផ្សព្វផ្សាយនេះក្រោមអធិបតីភាព **ឯកឧត្តម ហឿង សុគន្ធ** អភិបាលរង នៃគណៈអភិបាលខេត្តបាត់ដំបង **ឯកឧត្តម ម៉េងហុង** នាយករង ប.ស.ស និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស៕

✵នាថ្ងៃព្រហស្បតិ៍ ២រោច ខែមាឃ ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយរដ្ឋបាលខេត្តព្រះវិហារ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម និងផ្តល់ប័ណ្ណសមាជិក ប.ស.ស ជូនដល់មន្ត្រីរាជការ រដ្ឋបាលខេត្ត រដ្ឋបាលស្រុក និងមន្ត្រីជាប់កិច្ចសន្យានៃខេត្តព្រះវិហារ ដោយមានអ្នកចូលរួមចំនួន១៥០នាក់។ កិច្ចប្រជុំនេះផ្សព្វផ្សាយនេះក្រោមអធិបតីភាព **ឯកឧត្តម អ៊ុន ចាន់ដា** អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ **លោក យ៉ាម យុទ្ធា** អនុប្រធានការិយាល័យ ប.ស.ស សាខាខេត្តកំពង់ស្ពឺ ក្នុងឱកាសនោះបាន ប្រគល់ប័ណ្ណសមាជិករបស់ខ្លួន ដល់មន្ត្រីរាជការ រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងមន្ត្រីជាប់កិច្ចសន្យា នៃរដ្ឋបាលខេត្តព្រះវិហារ ចំនួន៣០៨ប័ណ្ណ៕



⁕នាថ្ងៃចន្ទ ១៤ កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយរដ្ឋបាលខេត្តកោះកុង បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ជូនដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃសាលាខេត្តកោះកុង ដោយមានអ្នកចូលរួមចំនួន៥០នាក់។ កិច្ចប្រប្រជុំនេះផ្សព្វផ្សាយនេះក្រោមអធិបតីភាព **ឯកឧត្តម ស្រេង ហុង** អភិបាលស្តីទីនៃគណៈអភិបាលខេត្ត តំណាង**លោកជំទាវ មិថុនា ភូថង** អភិបាលខេត្ត នៃគណៈអភិបាលខេត្តកោះកុង **លោក សុក បូរ៉ា** ប្រធានការិយាល័យតាវការលិក នៃ ប.ស.ស ក្នុងឱកាសនោះបាន ប្រគល់ប័ណ្ណសមាជិករបស់ខ្លួន ដល់មន្ត្រីរាជការសាលាខេត្ត/ក្រុង/ស្រុក ចំនួន ២០៩ប័ណ្ណ៕




⁕នាថ្ងៃព្រហស្បតិ៍ ១០ កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ-និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយរដ្ឋបាលខេត្តបន្ទាយមានជ័យ រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃរដ្ឋបាលខេត្តបន្ទាយមានជ័យ ដោយមានអ្នកចូលរួមចំនួន១៧០នាក់។កិច្ចប្រជុំផ្សព្វផ្សាយនេះក្រោមអធិបតីភាព **ឯកឧត្តម អ៊ុំ រាត្រី** អភិបាលរង តំណាងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ **លោក សុក បូរ៉ា** ប្រធានការិយាល័យតាវការលិក នៃ ប.ស.ស ព្រមទាំងមានការអញ្ជើញ ចូលរួមពីមន្ត្រី មន្ត្រីជាប់កិច្ចសន្យារដ្ឋបាលខេត្ត ក្រុង/ស្រុក៕





❈ នាថ្ងៃពុធ ៩កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមការងារ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយរដ្ឋបាលខេត្តកំពង់ចាម រៀប ចំកិច្ចប្រជុំផ្សព្វផ្សាយ អំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃរដ្ឋបាលខេត្តកំពង់ចាម។ កិច្ចប្រជុំនេះផ្សព្វផ្សាយនេះក្រោមអធិបតីភាព **ឯកឧត្តម កៅ សុខអាន** អភិបាលរង តំណាងឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម **លោក សុក ម៉ូរ៉ា** ប្រធានការិយាល័យតាវការលិក នៃ ប.ស.ស ព្រមទាំងមានការអញ្ជើញចូលរួមពីសំណាក់ លោក លោកស្រី តំណាងមន្ទីរ អង្គភាព និងស្ថាប័នពាក់ព័ន្ធនានា ចំនួន៧០នាក់៕



❈ នាថ្ងៃចន្ទ ៧កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមការងារ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយរដ្ឋបាលខេត្តស្ទឹងត្រែង រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃរដ្ឋបាល ខេត្តស្ទឹងត្រែង។ កិច្ចប្រជុំនេះផ្សព្វផ្សាយនេះក្រោមអធិបតីភាព **ឯកឧត្តម ញៀម សារី** អភិបាលរង និងជាតំណាងឯកឧត្តមអភិបាល នៃគណៈអភិបាល ខេត្តស្ទឹងត្រែង **ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស និងជាតំណាង **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស ដោយមានការចូលរួមពីសំណាក់ លោក លោកស្រី តំណាងមន្ទីរ អង្គភាព និងស្ថានប័នពាក់ព័ន្ធនានា សរុបប្រមាណជាង ១៧០ នាក់៕



❈ ក្រុមការងារ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ បានសហការជាមួយរដ្ឋបាលខេត្តពោធិ៍សាត់ រៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃរដ្ឋបាលខេត្តពោធិ៍សាត់។ កិច្ចប្រជុំនេះផ្សព្វផ្សាយនេះក្រោមអធិបតីភាព **ឯកឧត្តម ចេង ឡៃ** អភិបាលរងខេត្ត និងជាតំណាងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ **លោក សុក ម៉ូរ៉ា** ប្រធានការិយាល័យតាវការលិក នៃ ប.ស.ស ដោយមានការចូលរួមពីសំណាក់ លោក លោកស្រី តំណាងមន្ទីរ អង្គភាព និងស្ថាប័នពាក់ព័ន្ធនានា សរុបប្រមាណជាង ១០០នាក់៕





# លោក អគ្គបណ្ឌិត ប៊ុត សាវង្ស "កូនមាសឪពុក"

ឪពុកសូមឱ្យកូន ប្រើប្រាស់ពេលវេលា ឱ្យបាននូវប្រយោជន៍ច្រើនជាទីបំផុតក្នុងជីវិតរបស់កូន។ ពេលទំនេរ សូមឱ្យកូនចាប់សៀវភៅនេះយកមកអាន ហើយចាំទុកនូវសេចក្តីនីមួយៗផង។ ពេលមានទុក្ខ សូមឱ្យកូនពិចារណាតាមការណែនាំរបស់ឪនៅក្នុងសៀវភៅនេះឯង។ពេលបានសុខ សូមឱ្យកូនចាប់សៀវភៅនេះមករីករាយសប្បាយ ជាមួយឪពុកម្តាយ និងមានសេចក្តីសុខជាមួយក្រុមគ្រួសារដែរ។ពេលកូនមានបញ្ហា សូមឱ្យកូនប្រឹក្សាជាមួយឪពុកម្តាយ តែបើ ឪពុកម្តាយមិននៅទេ សូមឱ្យកូនប្រឹក្សាជាមួយសៀវភៅនេះចុះ។ ពុកនិងម៉ែ ប្រាថ្នាឱ្យកូនមាននូវសេចក្តីសុខ ទើបបានជាអប់រំ និងដាស់តឿនក្រើនរំលឹកកូនជារឿយៗ មិនឱ្យកូនលេងហួ ពេលវេលា ព្រោះអាចនាំឱ្យកូនមានជំងឺគ្រុនរងាជាដើមដាស់តឿនកូនមិនឱ្យញ៉ាំនូវអាហារណាដែលមិនល្អ ព្រោះវាអាច នាំឱ្យខូចសុខភាព ហើយបើកូននៅមិនទាន់យល់នូវពាក្យ ដាស់តឿន ឬក៏មិនស្តាប់តាមនូវពាក្យទូន្មាន របស់ម៉ែឪទេនោះ ដល់ពេលកូនមិនស្រួលខ្លួនឡើង ឪពុកម្តាយក៏ត្រូវតែនៅរក្សា និងព្យាបាលកូន យ៉ាងល្អជាទីបំផុតដដែល។ នៅក្នុងដំណើរជីវិតក៏ដូចគ្នាដែរ ឪពុកម្តាយបានព្យាយាមអប់រំ និងដាស់តឿនជានិច្ច ឱ្យកូនតាំងចិត្តសិក្សារៀនសូត្រ រៀបចំខ្លួនឱ្យនៅក្នុងសេចក្តីល្អ មិនឱ្យកូនប្រព្រឹត្តខ្លួនជាមនុស្សឡេះឡោះ តែបើពេលណាដែលកូនប្រព្រឹត្តភ្លាំងភ្លាត់ ដោយហេតុណាមួយនោះ ឪពុកម្តាយក៏នឹងព្យាយាមជួយកូនយ៉ាងប្តូរជីវិត ដូចជាពេលដែលកូនមិនស្រួលផ្លូវកាយដូច្នោះឯង ។ ព្រោះហេតុដូចពោលមកនេះ ឪសូមឱ្យកូនមានការចាំជា និច្ចថា ពេលណាដែលកូនមានូវបញ្ហាកើតឡើងសូមឱ្យ កូនប្រឹក្សាជាមួយនឹងម៉ែឪ កុំលាក់លៀមឱ្យសោះព្រោះ មិនមានអ្នកណាស្មោះត្រង់ និងមានបំណងជួយកូនឱ្យ ក្រៃលែងជាងម៉ែឪរបស់កូនឡើយ បើម៉ែឪដឹងហើយមិនថាបញ្ហានោះលំបាកលំបិនយ៉ាងណា ម៉ែឪរមែងរួមគ្នា ដោះស្រាយកែខៃបញ្ហាបានគ្រប់រឿងទាំងអស់។កូនមាសឪពុក កាលបើកូនបំពេញតួនាទីដោយសុចរិត ដោយការឆ្លាតវៃ មានសេចក្តីស្មោះត្រង់ និង កតញ្ញូកូន រមែងបានទទួលនូវសេចក្តីរីករាយ ព្រោះរលឹកឃើញអំពើ ដ៏បរិសុទ្ធរបស់ខ្លួន ហើយកូននឹងបានទទួលនូវផលសុខ មានសេចក្តីចម្រើនដល់អនាគតនៃជីវិតរបស់កូនព្រមទាំងក្រុមគ្រួសារយ៉ាងពិតប្រាកដ៕

# ៣យ៉ាង ពីហូបមើមត្រាវច្រើន មានប្រយោជន៍សុខភាព



ការបរិភោគ មើមត្រាវធម្មជាតិជួយច្រើនដល់សុខភាព សម្រួលការបញ្ចេញខ្យល់ និងអត្ថប្រយោជន៍សំខាន់ ៣យ៉ាង។

**១. សុខភាពពោះវៀន**

មើមត្រាវជាប្រភព ដ៏អស្ចារ្យមួយ ដែលមានផ្ទុកដោយជាតិសរសៃ។ ប្រជាជនអាមេរិកភាគច្រើន គឺមិនទទួលបានជាតិសរសៃគ្រប់គ្រាន់ពីរបបអាហារឡើយ ខណៈពេលដែលតម្រូវការប្រចាំថ្ងៃមនុស្សយើងជាមធ្យមប្រហែល១៥ក្រាម។

ស្ត្រីត្រូវការជាតិសរសៃ ២៥ក្រាមក្នុងមួយថ្ងៃ ខណៈ បុរស ៣៨ក្រាម។ ការទទួលទានមើមត្រាវ មិនត្រឹមតែជួយបំបាត់ការទល់លាមកទេ តែវាក៏ជួយបន្ថយការប្រឈមនឹងជំងឺបេះដូង និងទម្ងន់មានសុខភាពល្អដែរ។

**២. បញ្ចុះកូឡេស្តេរ៉ុល**

ជាតិសរសៃក្នុងមើមត្រាវ វាជាប្រភេទសរសៃមិនរលាយ ដែលត្រូវបានគេរកឃើញថា ជួយបន្ថយការប្រឈមនឹងជំងឺមហារីកពោះវៀនធំ ពង្រឹងដល់មុខងាររំលាយអាហារ និងមានទម្ងន់សុខភាពល្អ។ ជាតិសរសៃមិនរលាយ ជួយបញ្ចុះកូឡេស្តេរ៉ុល និងសម្ពាធឈាមដែរ។កាលណាសម្ពាធឈាមចុះមកធម្មតា ហើយមិនលើសកូឡេស្តេរ៉ុលក្នុងឈាមទៀត នោះអ្នក នឹងមិនងាយមានជំងឺបេះដូងឡើយ។

**៣. សម្រួលដល់សម្ពាធឈាម**

ការសិក្សាខ្លះបានបង្ហាញថា វាមានទំនាក់ទំនងមួយរវាងសម្ពាធឈាម និងរបបអាហារសម្បូរជាតិប៉ូតាស្យូម។ ការញ៉ាំជាតិប៉ូតាស្យូមកាន់តែច្រើន ត្រូវបានគេរកឃើញថា ជួយបន្ថយសម្ពាធឈាមដែលលើសបាន។អ្វីដែលសំខាន់នោះ និងការពិតនោះគឺថា កាលណាសម្ពាធឈាមកាន់តែខ្ពស់ អ្នកប្រឈមកាន់តែខ្លាំងនឹងជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺបេះដូង និងដាច់សរសៃឈាមខួរក្បាល។ ប៉ូតាស្យូមនឹងជួយបន្ធូរសរសៃឈាមដែលអាចបន្ថយការប្រឹងខ្លាំងរបស់បេះដូងបានដែរ៕

ប្រភព:http://news.sabay.com.kh/article/1099886#utm_campaign=onpage

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ២ដង ក្នុង ១ខែ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា កន្លងទៅ រោងចក្រ សហគ្រាស តែងតែបើកផ្តល់ប្រាក់ឈ្នួលប្រចាំខែដល់កម្មករនិយោជិតរបស់ខ្លួន នៅចន្លោះថ្ងៃទី០១ ដល់ថ្ងៃទី០៧ នៃខែបន្ទាប់ ដោយសាររោងចក្រ សហគ្រាស ត្រូវគណនាចំនួនថែមម៉ោង ចំនួនផលិតផលដែលសម្រេចបាន និងប្រាក់លើកទឹកចិត្តផ្សេងៗទៀតក្នុងខែនីមួយៗ។ ដោយឡែកចាប់ពីខែមករា ឆ្នាំ២០១៩ នេះតទៅ រោងចក្រ សហគ្រាស នឹងបើកផ្តល់ប្រាក់ឈ្នួលសុទ្ធសាធចំនួន ៥០% ឱ្យដល់កម្មករនិយោជិតនៅចន្លោះពីថ្ងៃទី១៦ ដល់ថ្ងៃទី១៩ នៃខែនីមួយៗ និងបើកផ្តល់ប្រាក់ឈ្នួលសរុបដែលនៅសល់ឱ្យដល់កម្មករនិយោជិត ចន្លោះពីថ្ងៃទី០១ ដល់ថ្ងៃទី០៧ នៃខែបន្ទាប់។

គិតត្រឹមរសៀលថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការពិនិត្យតាមដានអំពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត២ដង ក្នុង១ខែ នេះ ឃើញថា រោងចក្រ សហគ្រាស ចំនួន ៨១% បាននឹងកំពុងអនុវត្តការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន២ដង ក្នុង១ខែ ស្របតាមប្រកាសលេខ៤៤២ ក្នុងនោះ ៖

១-រោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ប្រមាណ៥០% អនុវត្តការបើកប្រាក់ឈ្នួលលើកទី១ នៅចន្លោះថ្ងៃទី១៦ ដល់ថ្ងៃទី១៩ នៃខែមករានេះ និងបើកលើកទី២ នៅចន្លោះថ្ងៃទី០១ ដល់ថ្ងៃទី០៧ នៃខែបន្ទាប់។

២-រោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ប្រមាណ២៥% អនុវត្តការបើកប្រាក់ឈ្នួលលើកទី១ នៅថ្ងៃទី១៦ ខែមករា នេះ និងបើកលើកទី២ នៅថ្ងៃទី០១ នៃខែបន្ទាប់។

៣-រោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ប្រមាណ២៥% អនុវត្តការបើកប្រាក់ឈ្នួលលើកទី១ នៅថ្ងៃទី២៥ ខែមករា នេះ និងលើកទី២ នៅថ្ងៃទី១០ នៃខែបន្ទាប់។

ចំពោះ រោងចក្រ សហគ្រាស ដែលកំពុងរៀបចំអនុវត្ត ក្រសួងនឹងធ្វើការត្រួតពិនិត្យ ដើម្បីជំរុញឱ្យអនុវត្ត ក្នុងករណីមិនអនុវត្ត នឹងត្រូវជាកពិន័យតាមច្បាប់ស្តីពីការងារ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ១១កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៩



# បេឡាជាតិរបបសន្តិសុខសង្គម

## National Social Security Fund


០២៣ ៨៨ ២៤ ៣៤
០២៣ ៩៩ ៨៤ ១៧
០២៣ ៩៩ ៨៤ ១៨
០២៣ ៩៩ ៨៨ ១៩
០២៣ ៨៨ ២៦ ២៣

បេឡាជាតិរបបសន្តិសុខសង្គម
NSSF Official
www.nssf.gov.kh
info@nssf.gov.kh

អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
(បរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)


